# សេចក្តីណែនាំស្តីពីការបំពេញទិន្នន័យក្នុងបញ្ជីកត់ត្រា ការសម្រាលកូនសម្រាប់មណ្ឌលសុខភាព

សេចក្តីណែនាំទូទៅ ៖

- បញ្ជីកត់ត្រានេះត្រូវប្រើនៅក្នុងបន្ទប់សម្រាលកូននិងត្រូវសរសេរ និងចុះហត្ថលេខាផ្ទាល់ ដោយបុគ្គលិកបង្កើតកូននីមួយៗ។
- បំពេញបញ្ជីកត់ត្រានេះព្រមទាំងធ្វើការសរុបទិន្នន័យប្រចាំខែដោយប្រើប្រាស់ទម្រង់សរុបនិងបញ្ចូលទិន្នន័យទៅក្នុងរបាយការណ៍ប្រចាំខែ(បិទបញ្ជីនៅថ្ងៃចុងក្រោយនៃខែនីមួយៗ)។
- សរសេរកាលបរិច្ឆេទនៃខែនីមួយៗនៅចំកណ្តាលនៃសៀវភៅបញ្ជីកត់ត្រាត្រូវប្រើទំព័រថ្មីសម្រាប់ចាប់ផ្តើមខែថ្មី។
- ចាប់ផ្តើមបន្ទាត់ថ្មីរាល់ការមកសម្រាលកូនសម្រាប់ស្ត្រីម្នាក់ៗ។ មិនត្រូវទុកបន្ទាត់នៅទំនេរ លើកលែងតែការចាប់ផ្តើមទំព័រថ្មីនៃខែបន្ទាប់។

ត្រូវបំពេញព័ត៌មានលម្អិតនៅបន្ទាត់ (ជួរផ្តេក) ដូចជាការណែនាំខាងក្រោមនូវគ្រប់ករណីទាំងអស់ ៖

| ខ្ទង់ទី | សេចក្តីណែនាំ |
|---|---|
| ១ | *លេខរៀង*<br>ជាលេខរៀងតាមលំដាប់ដែលស្ត្រីមកសម្រាលកូនក្នុងខែនីមួយៗជារៀងរាល់ខែ។ លេខរៀងនេះត្រូវចាប់ផ្តើមពីលេខ១ និងលេខបន្តបន្ទាប់រហូតដល់ដាច់ខែ (បិទបញ្ជីនៅថ្ងៃចុងក្រោយនៃខែនីមួយៗ)។ នៅពេលចាប់ផ្តើមខែថ្មី លេខរៀងនេះត្រូវចាប់ផ្តើមពីលេខ ១ឡើង។ |
| ២ | *លេខសៀវភៅសុខភាពមាតា*<br>ជាលេខសៀវភៅសុខភាពមាតា ដែលបានផ្តល់ជូនស្ត្រី នៅអំឡុងពេលមកតាមដានផ្ទៃពោះ និងទារក។ ឧទាហរណ៍៖ ដូចជាលេខសៀវភៅ ០០០១។ |
| ៣ | *ឈ្មោះ*<br>សរសេរឈ្មោះពេញ (នាមត្រកូល និងនាមខ្លួន) របស់ស្ត្រីដែលមកសម្រាលកូន។ |
| ៤ | *អាយុ*<br>សរសេរអាយុពិតប្រាកដរបស់ស្ត្រីមកសម្រាលកូនដូចជា ២៥ (មិនបាច់សរសេរអក្សរឆ្នាំ)។ |
| ៥ | *អាសយដ្ឋានបច្ចុប្បន្ន និងលេខទូរស័ព្ទ*<br>សរសេរ អាសយដ្ឋានបច្ចុប្បន្ន របស់ស្ត្រីដែលមកសម្រាលកូន។ ត្រូវសរសេរ ភូមិ ឃុំ/សង្កាត់ ស្រុក/ក្រុង/ ខណ្ឌ ខេត្ត/រាជធានី និងលេខទូរស័ព្ទ។ |
| ៦ | *បញ្ជូនមកពី*<br>សរសេរឈ្មោះទីកន្លែង ឬមូលដ្ឋានសុខាភិបាលដែលបញ្ជូនស្ត្រីមក។ សរសេរលេខ ០ប្រសិនបើមិនមានការបញ្ជូន |
| ៧ | *ថ្ងៃ ខែ ឆ្នាំ/ម៉ោងចូល*<br>សរសេរលេខថ្ងៃខែឆ្នាំ និងម៉ោងដែលស្ត្រីចូលមកមណ្ឌលសុខភាព។ ឧទាហរណ៍៖ ស្ត្រីចូលថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ម៉ោង១៥ និង៣០នាទីត្រូវសរសេរលេខ 17/1/12ម៉ោង 15:30។ |

នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល
ការិយាល័យប្រព័ន្ធព័ត៌មាន

USAID ជំនួយពីពលរដ្ឋអាមេរិក

BETTER HEALTH SERVICES

URC Cambodia

| ខ្ទង់ទី | សេចក្តីណែនាំ |
|---|---|
| ៨ | *ប្រវត្តិសម្រាលកូន - ចំនួនផ្ទៃពោះ/ សម្រាលកូន/ រលូត/ រំលូតពីមុនមក*<br>សរសេរចំនួនផ្ទៃពោះ និងចំនួនសម្រាលកូន រលូត រំលូត លើកមុន ដោយរួមបញ្ចូលការមានផ្ទៃពោះលើកនេះ ដូចជា G1P0A0 ។ G1=ផ្ទៃពោះលើកទី១ P0=មិនដែលមានប្រវត្តិសម្រាលកូនលើកមុន A0=មិនដែលមានប្រវត្តិរលូតកូនលើកមុន។ |
| ៩ | *អាយុផ្ទៃពោះគិតជាសប្តាហ៍*<br>ត្រូវសរសេរអាយុផ្ទៃពោះរបស់ស្ត្រីគិតជាសប្តាហ៍ដោយរាប់ចាប់ពីថ្ងៃទីមួយនៃការបាត់រដូវ ចុងក្រោយ (មិនបាច់សរសេរអក្សរសប្តាហ៍) ។ ឧទាហរណ៍៖ ៤០ |
| ១០ | *បញ្ជូនទៅសម្រាលកូននៅកន្លែងផ្សេង*<br>គូសសញ្ញាធីក (✓) ប្រសិនបើបញ្ជូនស្ត្រីទៅសម្រាលកូននៅកន្លែងផ្សេង។ សរសេរលេខ 0 ប្រសិនបើមិនមានការបញ្ជូន |
| ១១ | *កាលបរិច្ឆេទ/ម៉ោងសម្រាលកូន*<br>សរសេរថ្ងៃ ខែ ឆ្នាំសម្រាប់កាលបរិច្ឆេទ ហើយម៉ោង និងនាទី សម្រាប់ការសម្រាល។ ឧទាហរណ៍៖ ស្ត្រីសម្រាលថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ម៉ោង១៥ និង៣០នាទីត្រូវសរសេរលេខ 17/1/12ម៉ោង 15:30។ |
| ១២ | *សម្រាលកូននៅផ្ទះ*<br>សូមសរសេរលេខកូដដូចខាងក្រោម៖<br>• TBA: ប្រសិនបើសម្រាលដោយឆ្មបបុរាណ<br>• MW: ប្រសិនបើសម្រាលដោយបុគ្គលិកសុខាភិបាល (ប៉ុន្តែសម្រាលនៅផ្ទះ)។ |
| ១៣ | *ប្រភេទនៃការសម្រាល-សម្រាលធម្មតា*<br>គូសសញ្ញាធីក (✓) ប្រសិនបើស្ត្រីសម្រាលកូនធម្មតា |
| ១៤ | *ប្រភេទនៃការសម្រាល-សម្រាលដោយមានអន្តរាគមន៍*<br>សូមសរសេរអក្សរកាត់ពីអន្តរាគមន៍ណាមួយដែលអ្នកបានប្រើនៅពេលសម្រាល៖<br>• V = បូម<br>• O= ផ្សេងៗ |
| ១៥ | *ចាក់ Oxytocin ដល់ស្ត្រី (ក្នុងដំណាក់កាលទី៣នៃការសម្រាល)*<br>គូសសញ្ញាធីក (✓) ប្រសិនបើស្ត្រីត្រូវបានចាក់ Oxytocin នៅក្នុងដំណាក់កាលទី៣ នៃការសម្រាល សរសេរលេខ 0 ប្រសិនបើមិនបានចាក់ |
| ១៦ | *ផលវិបាកការសម្រាលកូន - ម្តាយ*<br>សរសេរផលវិបាករបស់ម្តាយពេលសម្រាលកូន។ ឧទាហរណ៍៖ មានធ្លាក់ឈាម, ក្រឡាភ្លើង ឬប្រកាច់ ការជួយសម្រាល ដោយប្រើតង្កៀប ឬបូម ការដាច់រហែកកំរិតទីបី ការក្លាយរោគ ជំងឺស្វាយផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ ស្លេកស្លាំងនិងជំងឺដទៃទៀតប្រសិនបើមាន។ ប្រសិនបើគ្មានករណីផលវិបាកទេ សូមសរសេរលេខ 0 |
| ១៧ | *ផលវិបាកការសម្រាលកូន-ទារក*<br>សរសេរផលវិបាករបស់កូនពេលសម្រាល។ ឧទាហរណ៍៖ កើតមកសន្លប់ ស្លេកស្លាំង ប្រកាច់ កើតមិនគ្រប់ខែ កើតទម្រង់គូទ, កូនកើតក្រោមទម្ងន់, ខាន់លឿង។ ប្រសិនបើគ្មានករណីផលវិបាកទេ សូមសរសេរលេខ 0 |
| ១៨ | *ទារកក្រោយសម្រាល- កើតរស់*<br>គូសសញ្ញាធីក (✓) ប្រសិនបើទារកកើតរស់។ |

<table>
<tr><th>ខ្ទង់ទី</th><th>សេចក្តីណែនាំ</th></tr>
<tr><td>១៩</td><td>ទារកក្រោយសម្រាល-កើតស្លាប់/ស្លាប់កើតថ្មីៗ/ស្លាប់កើតយូរ<br>សូមសរសេរលេខកូដដូចខាងក្រោម៖<ul><li>១= ទារកទើបនឹងកើតស្លាប់តិចជាង២៤ម៉ោង។</li><li>២= ទារកទើបនឹងកើតស្លាប់លើសពី២៤ម៉ោង។</li><li>៣= ទារកស្លាប់កើតថ្មីៗ Fresh Stillbirth (មិនមានសញ្ញាទន់ ឬរលួយស្បែកទេ ស្បែកដូចទារកកើតរស់)។ ទារកស្លាប់ពេលឈឺពោះសម្រាល ឬពេលសម្រាលកូន។</li><li>៤= ទារកស្លាប់កើតយូរ Macerated stillbirth (មានសញ្ញាទន់ឬរលួយស្បែក)។ ទារកស្លាប់មុនពេលឈឺពោះសម្រាលកូន ទារកមិនមានចង្វាក់បេះដូងមុនពេលឈឺពោះសម្រាល។</li></ul></td></tr>
<tr><td>២០</td><td>ទារកក្រោយសម្រាល - ភេទ<br>សូមសរសេរ M សម្រាប់ភេទប្រុសឬ  F សម្រាប់ភេទស្រី។ បើកូនភ្លោះ សូមសរសេរពីរជួរ (ផ្តេក) តែមិនត្រូវដាក់លេខរៀងសម្រាប់កូនទេ។</td></tr>
<tr><td>២១</td><td>ទម្ងន់ទារក <2500ក្រាម<br>សរសេរទម្ងន់ជាក់ស្តែងរបស់ទារកដែលមានទម្ងន់តិចជាង ២៥០០ក្រ។ ឧទាហរណ៍៖ ២០០០ក្រ</td></tr>
<tr><td>២២</td><td>ទម្ងន់ទារក ≥ 2500ក្រាម<br>សរសេរទម្ងន់ជាក់ស្តែងរបស់ទារកដែលមានទម្ងន់ស្មើ ឬលើសពី ២៥០០ក្រ។ ឧទាហរណ៍៖ ៣០០០ក្រ</td></tr>
<tr><td>២៣</td><td>ទារកដកដង្ហើមក្នុង១នាទីដំបូង<br>គូសសញ្ញាធីក (✓) ប្រសិនបើទារកដកដង្ហើមក្នុង១នាទីដំបូង។ សរសេរលេខ 0ប្រសិនបើទារកមិនបានដកដង្ហើម១នាទីដំបូង</td></tr>
<tr><td>២៤</td><td>ការប៉ះផ្ទាល់នឹងម្តាយ<br>គូសសញ្ញាធីក (✓) ប្រសិនបើទារកប៉ះផ្ទាល់ជាមួយម្តាយនៅក្នុងបន្ទប់សម្រាល។ សរសេរលេខ 0 ប្រសិនបើទារកមិនបានប៉ះផ្ទាល់ជាមួយម្តាយទេ។</td></tr>
<tr><td>២៥</td><td>បំបៅដោះកូនក្នុង១ម៉ោងដំបូង<br>គូសសញ្ញាធីក (✓) ប្រសិនបើទារកបានបំបៅដោះក្នុង១ម៉ោងដំបូង។ សរសេរលេខ 0 ប្រសិនបើទារកមិនបានបំបៅដោះក្នុង១ម៉ោងដំបូង។</td></tr>
<tr><td>២៦</td><td>លទ្ធផល HIV-លេខកូដសំណាកឈាម<br>សរសេរលេខកូដសំណាកឈាមរបស់ស្ត្រី។</td></tr>
<tr><td>២៧</td><td>លទ្ធផលHIV - ស្ថានភាពមេរោគអេដស៍ HIV<br>បើស្ត្រីនោះធ្លាប់ធ្វើតេស្ត HIV ត្រូវសួរពីលទ្ធផល តេស្តនោះ បើលទ្ធផលតេស្តវិជ្ជមានត្រូវគូសសញ្ញា (+) បើលទ្ធផលអវិជ្ជមានត្រូវគូសសញ្ញា (-) ឬសរសេរមិនដឹង ប្រសិនបើមិនដឹងអំពីលទ្ធផល ឬសរសេរ (មិនធ្លាប់) បើមិនដែលធ្វើតេស្តឈាមរកមេរោគអេដស៍។</td></tr>
<tr><td>២៨</td><td>លទ្ធផលHIV - លទ្ធផលស្ថានភាពមេរោគអេដស៍ដែលបានធ្វើអំឡុងពេលសម្រាលកូន<br>សរសេរលទ្ធផល :<ul><li>បើលទ្ធផលតេស្ត HIV អវិជ្ជមានត្រូវគូសសញ្ញា (-)</li><li>បើលទ្ធផលតេស្ត HIV វិជ្ជមានត្រូវគូសសញ្ញា (+)</li><li>បើលទ្ធផលតេស្ត HIV មិនអាចកំណត់បានត្រូវសរសេរថា (កំណត់មិនបាន)</li></ul>ប្រសិនបើដឹងពីស្ថានភាពមេរោគអេដស៍ក្នុងខ្ទង់ទី២៧ ហើយត្រូវរំលងខ្ទង់ទី២៨ចោល។</td></tr>
</table>

<table>
<tr><th>ខ្ទង់ទី</th><th>សេចក្ដីណែនាំ</th></tr>
<tr><td>២៩</td><td><u>ម្ដាយ-ប្រវត្តិធ្លាប់បានទទួលART ឬថ្នាំបីមុខរួមបញ្ចូលគ្នាសម្រាប់បង្ការពីមុន</u><br>ប្រសិនបើម្ដាយមានប្រវត្តិធ្លាប់បានទទួល ART ឬថ្នាំបីមុខរួមបញ្ចូលគ្នាសម្រាប់បង្ការពីពេលមុនសូមសរសេរកូដដូចខាងក្រោម:<br>• ១= ទទួល ART<br>• ២= ទទួល ARV បង្ការបីមុខរួមបញ្ចូលគ្នា<br>• 0= មិនបានទទួល</td></tr>
<tr><td>៣០</td><td><u>ម្ដាយ-ទទួលថ្នាំARV សម្រាប់ពេលសម្រាល</u><br>សរសេរលេខកូដ :<br>• ១= ទទួល ARV<br>• 0= មិនបានទទួល</td></tr>
<tr><td>៣១</td><td><u>ទទួលARV - ARV សម្រាប់ទារក</u><br>សរសេរលេខកូដ :<br>• ១= ទទួល ARV<br>• 0= មិនបានទទួល</td></tr>
<tr><td>៣២</td><td><u>កាលបរិច្ឆេទ/ម៉ោងចេញ</u><br>សរសេរថ្ងៃ ខែ និងម៉ោងចេញ (ឧទាហរណ៍៖ ៣០/០២/២០១២ម៉ោង ១៦:៣៥)។</td></tr>
<tr><td>៣៣</td><td><u>បញ្ជូនម្ដាយ និងទារកទៅកន្លែងផ្សេង</u><br>គូសសញ្ញាធីក (✓) ប្រសិនបើបញ្ជូនម្ដាយទៅកន្លែងផ្សេង។ សរសេរលេខ 0 ប្រសិនបើមិនមានការបញ្ជូនទៅកន្លែងផ្សេង។</td></tr>
<tr><td>៣៤</td><td><u>មរណភាពមាតា</u><br>សរសេរមូលហេតុស្លាប់ ដូចខាងក្រោម៖<br>១= ធ្លាក់ឈាមជុំវិញកំណើត    ៤= រំលូតកូន/រលូត<br>២= ក្រឡាភ្លើង    ៥= មូលហេតុផ្សេងៗសូមសរសេរ។<br>៣= ការក្លាយរោគ</td></tr>
<tr><td>៣៥</td><td><u>ប្រភេទនៃការបង់ថ្លៃសេវា</u><br>• សូមសរសេរ P: ប្រសិនបើគាត់បង់លុយដោយខ្លួនឯង។<br>• សូមសរសេរ HEF: ប្រសិនបើបង់ដោយគម្រោងមូលនិធិសមធម៌។<br>• សូមសរសេរ CBHI: ប្រសិនបើបង់ដោយគម្រោងធានារ៉ាប់រងសហគមន៍។<br>• សូមសរសេរ V: ប្រសិនបើគាត់មានប័ណ្ណសុខភាព។<br>• សូមសរសេរ E: ប្រសិនបើគាត់ជាករណីលើកលែង។<br><br>ប្រសិនបើការបង់ថ្លៃសេវាដោយ HEF ឬCBHI ឬV សូមសរសេរលេខកូដដែលស្រង់ចេញពីប័ណ្ណនោះក្នុងខ្ទង់សម្គាល់។</td></tr>
<tr><td>៣៦</td><td><u>សម្គាល់</u><br>ត្រូវសរសេរចំណុចសម្គាល់ផ្សេងៗដែលទាក់ទងនឹងការសម្រាលកូន និងហត្ថលេខារបស់អ្នកបង្កើតកូន។</td></tr>
</table>

# សម្រង់ទិន្នន័យសម្រាលកូនសម្រាប់មណ្ឌលសុខភាព

| លេខខ្ទង់ក្នុងបញ្ជីកត់ត្រា | នៃខែ..............ឆ្នាំ............. | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | Total | Code |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៦ | បញ្ជូនមកពី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D1 |
| ១០ | បញ្ជូនទៅសម្រាលកូននៅកន្លែងផ្សេង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D2 |
| ១២ | សម្រាលកូននៅផ្ទះ | បុគ្គលិកសុខាភិបាល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D3 |
| | | ឆ្មបបុរាណ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D4 |
| ១៣ | ប្រភេទនៃការសម្រាល | សម្រាលធម្មតា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D5 |
| | | សម្រាលដោយបូម =V | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D6 |
| ១៤ | | អន្តរាគមន៍ផ្សេងៗ=O | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D7 |
| ១៥ | ចាក់ Oxytocin | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D7.1 |
| ១៦ | ផលវិបាកការសម្រាល-ម្តាយ | ធ្លាក់ឈាម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D8 |
| | | ការជួយសម្រាលដោយប្រើតង្កៀប | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D9 |
| | | បូម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D10 |
| | | ផ្សេងៗ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D12 |
| ១៧ | ផលវិបាកការសម្រាល-ទារក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D13 |
| ១៨ + ២០ | ទារកកើតរស់ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D14 |
| | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D15 |
| ១៩ + ២០ | ទារកកើតស្លាប់ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D16 |
| | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D17 |
| | ទារកស្លាប់កើតថ្មី Fresh stillbirth | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D18 |
| | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D19 |
| | ទារកស្លាប់កើតយូរ Macerate stillbirth | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D20 |
| | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D21 |

| លេខខ្ទង់ក្នុងបញ្ជីកត់ត្រា | នៃខែ.............ឆ្នាំ............ | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | Total | Code |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០ + ២១ | ទម្ងន់ទារក <2500ក្រាម | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D22 |
| | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D23 |
| ២០ + ២២ | ទម្ងន់ទារក ≥2500ក្រាម | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D24 |
| | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D25 |
| ២៣ | ទារកដកដង្ហើមក្នុង១នាទីដំបូង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D26 |
| ២៤ | ការប៉ះផ្ទាល់ជាមួយនឹងម្តាយ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D27 |
| ២៥ | បំបៅដោះកូនក្នុង១ម៉ោងដំបូង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D28 |
| ២៧ | ស្ថានភាពមេរោគអេដស៍ HIV | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D29 |
| ២៩ | ARVសម្រាប់ម្តាយ | ទទួល ART | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D31 |
| | | ARVបង្ការ (៣មុខ) | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D32 |
| ៣០ | | សម្រាប់ពេលសម្រាល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D33 |
| ៣១ | ARV សម្រាប់ទារក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D34 |
| ៣៣ | បញ្ជូនម្តាយ និងទារកទៅកន្លែងផ្សេង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D35 |
| ៣៤ | មរណភាពមាតា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D36 |
| ៣៥ | P: បង់លុយដោយខ្លួនឯង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D37 |
| | HEF: គម្រោងមូលនិធិសមធម៌ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D38 |
| | CBHI: ធានារ៉ាប់រងសុខភាពសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D39 |
| | V: ប័ណ្ណសុខភាព | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D40 |
| | P: ករណីលើកលែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | D41 |

# សេចក្តីណែនាំស្តីពីការបំពេញទិន្នន័យ
# ក្នុងសម្រង់ទិន្នន័យការសម្រាលកូនសម្រាប់មណ្ឌលសុខភាព

| ល.រ | ទិន្នន័យ | | លេខកូដ | HMIS | ការណែនាំ |
|---|---|---|---|---|---|
| ១ | បញ្ជូនមកពី | | D1 | | រាប់ចំនួនស្ត្រីដែលបានបញ្ជូនមកពីកន្លែងផ្សេង នៅក្នុងខ្ទង់ទី៦ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ២ | បញ្ជូនទៅសម្រាលកូននៅកន្លែងផ្សេង | | D2 | | រាប់ចំនួនស្ត្រីដែលបានបញ្ជូនទៅសម្រាលនៅកន្លែងផ្សេង នៅក្នុងខ្ទង់ទី១០ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣ | សម្រាលកូននៅផ្ទះ | បុគ្គលិកសុខាភិបាល | D3 | | រាប់ចំនួនស្ត្រីសម្រាលកូននៅផ្ទះ ដោយបុគ្គលិកសុខាភិបាល ដែលតាងដោយអក្សរ MW នៅក្នុងខ្ទង់ទី១២ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៤ | | ឆ្មបបុរាណ | D4 | | រាប់ចំនួនស្ត្រីសម្រាលកូននៅផ្ទះ ដោយឆ្មបបុរាណ ដែលតាងដោយអក្សរ TBA នៅក្នុងខ្ទង់ទី១២ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៥ | ប្រភេទនៃការសម្រាល | សម្រាលធម្មតា | D5 | | រាប់ចំនួនស្ត្រីសម្រាលកូនធម្មតា នៅក្នុងខ្ទង់ទី១៣ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៦ | | សម្រាលដោយបូម =V | D6 | | រាប់ករណីស្ត្រីសម្រាលកូន ដោយបូម ដែលតាងដោយអក្សរ V នៅក្នុងខ្ទង់ទី១៤ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៧ | | អន្តរាគមន៍ផ្សេងៗ=O | D7 | | រាប់ករណីស្ត្រីសម្រាលកូន ដោយករណីផ្សេងៗ ដែលតាងដោយអក្សរ O នៅក្នុងខ្ទង់ទី១៤ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៨ | ចាក់ Oxytocin | | D7.1 | | រាប់ករណីស្ត្រីសម្រាលកូនដោយបានចាក់ Oxytocin នៅក្នុងខ្ទង់ទី១៥ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៩ | ផលវិបាកការសម្រាល-ម្តាយ | ធ្លាក់ឈាម | D8 | | រាប់ករណីស្ត្រីមកសម្រាលកូនដោយមានធ្លាក់ឈាម នៅពេលសម្រាលកូន នៅក្នុងខ្ទង់ទី១៦ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ១០ | | ក្រឡាភ្លើង | D9 | | រាប់ករណីស្ត្រីមកសម្រាលកូនដោយមានក្រឡាភ្លើងនៅក្នុងខ្ទង់ទី១៦ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ១១ | | រហែកស្បូន | D10 | | រាប់ករណីស្ត្រីមកសម្រាលកូនដោយមានរហែកស្បូននៅក្នុងខ្ទង់ទី១៦ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ១២ | | ក្តាយរោគ | D11 | | រាប់ករណីស្ត្រីមកសម្រាលកូនដោយមានក្តាយរោគនៅក្នុងខ្ទង់ទី១៦ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ១៣ | | ផ្សេងៗ | D12 | | រាប់ករណីស្ត្រីមកសម្រាលកូនដោយមានផលវិបាកផ្សេងៗនៅក្នុងខ្ទង់ទី១៦ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ១៤ | ផលវិបាកការសម្រាល-ទារក | | D13 | | រាប់ករណីកូនដែលមានផលវិបាកពេលសម្រាល នៅក្នុងខ្ទង់ទី១៧ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ១៥ | ទារកកើតរស់ | ប្រុស | D14 | | រាប់ចំនួនទារកកើតរស់ នៅក្នុងខ្ទង់ទី១៨ និងភេទប្រុសដែលសរសេរអក្សរ M នៅក្នុងខ្ទង់ទី២០ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ១៦ | | ស្រី | D15 | | រាប់ចំនួនទារកកើតរស់ នៅក្នុងខ្ទង់ទី១៨ និងភេទស្រីដែលសរសេរអក្សរ F នៅក្នុងខ្ទង់ទី២០ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ១៧ | ទារកកើតស្លាប់ | ប្រុស | D16 | | រាប់ចំនួនទារកកើតស្លាប់ នៅក្នុងខ្ទង់ទី១៩ និងភេទប្រុសដែលសរសេរអក្សរ M នៅក្នុងខ្ទង់ទី២០ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ១៨ | | ស្រី | D17 | | រាប់ចំនួនទារកកើតស្លាប់ នៅក្នុងខ្ទង់ទី១៩ និងភេទស្រីដែលសរសេរអក្សរ F នៅក្នុងខ្ទង់ទី២០ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |

| ល.រ | ទិន្នន័យ | | លេខកូដ | HMIS | ការណែនាំ |
|---|---|---|---|---|---|
| ១៩ | ទារកស្លាប់កើតថ្មី Fresh stillbirth | ប្រុស | D18 | | រាប់ចំនួនទារកស្លាប់កើតថ្មី (Fresh stillbirth) នៅក្នុងខ្ទង់ទី១៩ និងភេទប្រុសដែលសរសេរអក្សរ M នៅក្នុងខ្ទង់ទី២០ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ២០ | | ស្រី | D19 | | រាប់ចំនួនទារកស្លាប់កើតថ្មី (Fresh stillbirth) នៅក្នុងខ្ទង់ទី១៩ និងភេទស្រីដែលសរសេរអក្សរ F នៅក្នុងខ្ទង់ទី២០ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ២១ | ទារកស្លាប់កើតយូរ Macerate stillbirth | ប្រុស | D20 | | រាប់ចំនួនទារកទារកស្លាប់កើតយូរ (Macerated Stillbirth) នៅក្នុងខ្ទង់ទី១៩ និងភេទប្រុសដែលសរសេរអក្សរ M នៅក្នុងខ្ទង់ទី២០ ពីបញ្ជីកត់ត្រាការសម្រាលកូនរបស់មណ្ឌលសុខភាព។ |
| ២២ | | ស្រី | D21 | | រាប់ចំនួនទារកទារកស្លាប់កើតយូរ (Macerated Stillbirth) ) នៅក្នុងខ្ទង់ទី១៩ និងភេទស្រីដែលសរសេរអក្សរ F នៅក្នុងខ្ទង់ទី២០ ពីបញ្ជីកត់ត្រាការសម្រាលកូនរបស់មណ្ឌលសុខភាព។ |
| ២៣ | ទម្ងន់ទារក <2500ក្រាម | ប្រុស | D22 | | រាប់ចំនួនទារកភេទប្រុស សរសេរដោយអក្សរ M នៅក្នុងខ្ទង់ទី២០ ដែលមានទម្ងន់តិចជាង 2500ក្រាម នៅក្នុងខ្ទង់២១ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ២៤ | | ស្រី | D23 | | រាប់ចំនួនទារកភេទស្រី សរសេរដោយអក្សរ F នៅក្នុងខ្ទង់ទី២០ ដែលមានទម្ងន់តិចជាង 2500ក្រាម នៅក្នុងខ្ទង់២១ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ២៥ | ទម្ងន់ទារក≥ 2500ក្រាម | ប្រុស | D24 | | រាប់ចំនួនទារកភេទប្រុស សរសេរដោយអក្សរ M នៅក្នុងខ្ទង់ទី២០ ដែលមានទម្ងន់ស្មើ ឬលើស 2500ក្រាម នៅក្នុងខ្ទង់២២ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ២៦ | | ស្រី | D25 | | រាប់ចំនួនទារកភេទប្រុស សរសេរដោយអក្សរ F នៅក្នុងខ្ទង់ទី២០ ដែលមានទម្ងន់ស្មើ ឬលើស 2500ក្រាម នៅក្នុងខ្ទង់២២ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ២៧ | ទារកដកដង្ហើមក្នុង១នាទីដំបូង | | D26 | | រាប់ចំនួនទារកដកដង្ហើមក្នុង១នាទីដំបូង ក្នុងខ្ទង់ទី២៣ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់ណ្ឌលសុខភាព។ |
| ២៨ | ការប៉ះផ្ទាល់ជាមួយនឹងម្តាយ | | D27 | | រាប់ករណីដែលទារកបានដាក់អោយប៉ះផ្ទាល់ជាមួយនឹងម្តាយ នៅក្នុងខ្ទង់ទី២៤ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ២៩ | បំបៅដោះកូនក្នុង១ម៉ោងដំបូង | | D28 | | រាប់ចំនួនស្ត្រីដែលបានបំបៅដោះកូនក្នុង១ម៉ោងដំបូង នៅក្នុងខ្ទង់ទី២៥ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣០ | ស្ថានភាពមេរោគអេដស៍ HIV | វិជ្ជមាន (+) | D29 | | រាប់ចំនួនស្ត្រីដែលមកសម្រាលកូនមានលទ្ធផលតេស្តមេរោគអេដស៍វិជ្ជមាន នៅក្នុងខ្ទង់ទី២៧ និង២៨ដែលមានសញ្ញាលេខបូក (+) ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣១ | | អវិជ្ជមាន (-) | D30 | | រាប់ចំនួនស្ត្រីដែលមកសម្រាលកូនមានលទ្ធផលតេស្តមេរោគអេដស៍អវិជ្ជមាន នៅក្នុងខ្ទង់ទី២៧ និង២៨ ដែលមានសញ្ញាលេខដក (-) ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣២ | ARVសម្រាប់ម្តាយ | ទទួល ART | D32 | | រាប់ចំនួនស្ត្រីដែលបានទទួល ART សរសេរដោយលេខ១ នៅក្នុងខ្ទង់ទី២៩ ពីបញ្ជីកត់ការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣៣ | | ARV (៣មុខ) | D33 | | រាប់ចំនួនស្ត្រីដែលបានទទួល ARV (៣មុខ) សរសេរដោយលេខ២ នៅក្នុងខ្ទង់ទី២៩ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣៤ | | សម្រាប់ពេលសម្រាល | D34 | | រាប់ចំនួនស្ត្រីដែលបានទទួល ARV សម្រាប់ពេលសម្រាល សរសេរដោយលេខ១ នៅក្នុងខ្ទង់ទី៣០ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |

| ល.រ | ទិន្នន័យ | លេខកូដ | HMIS | ការណែនាំ |
|---|---|---|---|---|
| ៣៥ | ARV សំរាប់ទារក | D35 | | រាប់ចំនួនទារកដែលបានទទួល ARV សរសេរដោយលេខ១ នៅក្នុងខ្ទង់ទី៣១ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣៦ | បញ្ជូនម្ដាយ និងទារកទៅកន្លែងផ្សេង | D36 | | រាប់ករណីបញ្ជូនម្ដាយ និងទារកទៅកន្លែងផ្សេង នៅក្នុងខ្ទង់ទី៣៣ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣៧ | មរណភាពមាតា | D37 | | រាប់ករណីមរណភាពមាតា នៅក្នុងខ្ទង់ទី៣៤ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣៨ | P: បង់លុយដោយខ្លួនឯង | D38 | | រាប់ករណីបង់លុយដោយខ្លួនឯង ដែលមានសរសេរអក្សរ P នៅក្នុងខ្ទង់ទី៣៥ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៣៩ | HEF: គម្រោងមូលនិធិសមធម៌ | D39 | | រាប់ការបង់ថ្លៃសេវាដោយគំរោងមូលនិធិសមធម៌ ដែលមានសរសេរអក្សរ HEF នៅក្នុងខ្ទង់ទី៣៥ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៤០ | CBHI: ធានារ៉ាប់រងសហគមន៍ | D40 | | រាប់ការបង់ថ្លៃសេវាដោយធានារ៉ាប់រងសហមគន៍ ដែលមានសរសេរអក្សរ CBHI នៅក្នុងខ្ទង់ទី៣៥ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៤១ | V: ប័ណ្ណសុខភាព | D41 | | រាប់ការបង់ថ្លៃសេវា ប្រសិនបើមានបណ្ណ័សុខភាព ដែលមានសរសេរអក្សរ V នៅក្នុងខ្ទង់ទី៣៥ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |
| ៤២ | E: ករណីលើកលែង | D42 | | រាប់ការបង់ថ្លៃសេវា ដោយករណីលើកលែង ដែលមានសរសេរអក្សរ E នៅក្នុងខ្ទង់ទី៣៥ ពីបញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព។ |

# របាយការណ៍សរុបប្រចាំខែផ្នែកគាំពារសុខភាពមាតានិងទារក

ការពិនិត្យផ្ទៃពោះមុនសំរាល-ការសំរាលកូន និង ពិនិត្យក្រោយសំរាល (Antenatal Cares , Delivery and Post-partum Cares)

| ទីកន្លែង | សរុបសម្រាលកូន | សម្រាលធម្មតា | សម្រាលលំបាក (ស្ពាបព្រាគៀប/បូម) | ធ្លាក់ឈាម | ស្ត្រីផ្ទុកមេរោគអេដស៍សម្រាលកូនបានទទួល ARV | ចំនួនមាតាស្លាប់ | បញ្ជូនទៅ |
|---|---|---|---|---|---|---|---|
| នៅមណ្ឌលសុខភាព | | | | | | | |
| នៅផ្ទះ (បុគ្គលិកសុខាភិបាល) | D3 | | | | | | |
| ឆ្មបបូរាណ | D4 | | | | | | |
| សរុប | | D5 | D6 | D8 | D33 | D36 | D2 |

កំណើតទារក (Births)

| ទំងន់ទារក | មិនបានថ្លឹង | | < 2 Kg | | 2Kg និង < 2,5 Kg | | ≥ 2,5 Kg | | **សរុបកើតរស់ *** | | កើតស្លាប់ | | ស្លាប់កើត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | **ប្រុស** | **ស្រី** | ប្រុស | ស្រី | |
| ចំនួនទារក | | | | | D22 | D23 | D24 | D25 | **D14** | **D15** | D16 | D17 | D18+....D21 |

សម្រាប់ព័ត៌មានលម្អិត សូមមើលនៅក្នុងសៀវភៅណែនាំពីបញ្ជីកត់ត្រា ឬចូលទៅកាន់គេហទំព័រ www.hiscambodia.org ។